មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

## <u>សេចក្តីថ្លែងការណ៍ របស់ ម.ស.ម.ក</u> – <u>ភ្នំពេញ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១២</u>

## <u>ម.ស.ម.ក អំពាវនាវឲ្យមានសមភាព និងភាពមិនរើសអើង ចំពោះស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ក្នុងវិស័យការងារ</u>

<u>មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា</u> (“ម.ស.ម.ក”) អំពាវនាវដល់ភ្នាក់ងាររដ្ឋាភិបាល ស្ថាប័ននានា អង្គការសង្គមស៊ីវិល សហជីពកម្មករ ជាពិសេសវិស័យឯកជន និងនិយោជកទាំងអស់ ឲ្យប្រយុទ្ធប្រឆាំងនឹងការស្អប់ខ្ពើមអ្នកស្រឡាញ់ភេទដូចគ្នានៅកន្លែងធ្វើការ។ ថ្ងៃទី១ ខែឧសភា គឺជាទិវាពលកម្មអន្តរជាតិ ដែលប្រទេសនានានៅទូទាំងពិភពលោក ទទួលស្គាល់សិទ្ធិរបស់កម្មករ ទើបនៅថ្ងៃនេះ យើងជម្រុញភាគីពាក់ព័ន្ធទាំងអស់នៅកម្ពុជា ឲ្យចូលរួមអបអរសាទរទិវាជាអន្តរជាតិនេះ ចំពោះការរួមចំណែក និងសមិទ្ធិផលរបស់កម្មករ ទាំងក្នុងវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច ហើយក៏ឆ្លៀតយកឱកាសនេះ អំពាវនាវឲ្យមានសមភាព ចំពោះអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ នៅក្នុងវិស័យការងារ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ធានាពីសិទ្ធិស្មើភាពគ្នា និងភាពមិនរើសអើង និងទទួលស្គាល់ភាពអនុវត្តន៍បាននៃច្បាប់សិទ្ធិមនុស្សអន្តរជាតិនៅក្នុងប្រទេសកម្ពុជា (មាត្រា៣១)។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ធានាពីសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ ក៏ដូចជាសិទ្ធិសង្គមកិច្ច វប្បធម៌ និងសេដ្ឋកិច្ច ដល់បុគ្គលគ្រប់ៗរូបដោយគ្មានការរើសអើងក្នុងការទទួលបាន/និងរក្សាការងារ។ អនុលោមតាមលិខិតូបករណ៍អន្តរជាតិស្តីពីសិទ្ធមនុស្សទាំងនេះ រដ្ឋមានកាតព្វកិច្ចការពារបុគ្គលពីការរើសអើង ក្នុងការទទួលបាន/និងរក្សាការងារ។ គណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានបញ្ជាក់ថា កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ “ហាមឃាត់ការរើសអើងក្នុងការទទួលបាន/និងរក្សាការងារ ដោយផ្អែកលើមូលដ្ឋាន … និន្នាការភេទ”។ ដូចគ្នានេះដែរ ការរើសអើងក្នុងវិស័យការងារ ត្រូវបានហាមឃាត់ដោយអនុសញ្ញាអង្គការពលកម្មអន្តរជាតិ “អនុសញ្ញាទាក់ទងនឹងការលុបបំបាត់ការរើសអើងក្នុងវិស័យការងារ និងមុខរបរ” ដែលកម្ពុជាបានផ្តល់សច្ចាប័នកាលពីឆ្នាំ១៩៩៩។

បើទោះបីជាមានបទប្បញ្ញត្តិដូចខាងលើក្តី ការរើសអើងប្រឆាំងនឹងអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ នៅកន្លែងធ្វើការ នៅតែបន្តកើតមាន ដោយសារតែកង្វះការយល់ដឹង និងការគោរពពីសង្គម និងនិយោជក។ ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មិនបានការពារនិយោជិតដែលជាអ្នកស្រឡាញ់ភេទដូចគ្នា ពីការរើសអើងចំពោះអ្នកស្រឡាញ់ភេទដូចគ្នា ទាំងនៅកន្លែងធ្វើការ និងពេលដាក់ពាក្យធ្វើការ។ ជារឿយៗ អ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ប្រឈមនឹងការផាត់ចេញពីសង្គម ការបៀតបៀន ការដាក់ងារ (ឧទហរណ៍ “ខ្ទើយ”) និងរងនូវការប្រមាថនៅកន្លែងធ្វើការ ដែលនាំឲ្យពួកគាត់បាក់ទឹកចិត្ត និងត្រូវប្រឈមនឹងបញ្ហាសេដ្ឋកិច្ច។ បុរសស្រឡាញ់បុរស ម្នាក់បានរាយការណ៍មក ម.ស.ម.ក ថានៅពេលដែលគាត់បើកចំហរនិន្នាការភេទរបស់គាត់នៅកន្លែងធ្វើការ គាត់ទទួលរងនូវការប្រមាថយ៉ាងខ្លាំងរហូតដល់គាត់បង្ខំចិត្តលាលែងឈប់ធ្វើការ។ បុរសដែលប្តូរភេទជាស្ត្រី និងស្ត្រីដែលប្តូរភេទជាបុរសនៅកម្ពុជា បានរាយការណ៍ថា ជាញឹកញាប់ ដោយសារតែរូបរាងខាងក្រៅរបស់ពួកគាត់ ពួកគាត់ត្រូវបានគេបដិសេធមិនឲ្យធ្វើការងារ សូម្បីតែនៅតាមភោជនីយដ្ឋាន និងរោងចក្រកាត់ដេរ បើទោះណាជាគាត់បានបញ្ចប់ការសិក្សាក៏ដោយ ហើយរហូតមានករណីខ្លះពួកគាត់ត្រូវបង្ខំចិត្តរកស៊ីផ្លូវភេទ។ ជាធម្មតា អ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ចាំបាច់ត្រូវលាក់អត្តសញ្ញាណរបស់ពួកគាត់នៅពេលធ្វើការ ស្ត្រីស្រឡាញ់ស្ត្រីនៅកម្ពុជា ប្រាប់យើងថា *“ទោះបីមិត្តភ័ក្តខ្ញុំ ដែលជាស្ត្រីស្រឡាញ់ស្ត្រីតុបតែងខ្លួនជាប្រុស តែខ្ញុំតុបតែងខ្លួនជាស្ត្រី ព្រោះខ្ញុំត្រូវការស្វែងរកការងារធ្វើ និងរកប្រាក់ចិញ្ចឹមជីវិត”*។

**លោក ហែម សុខលី មន្ត្រីសម្របសម្រួលគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ប្រចាំនៅ ម.ស.ម.ក បានលើកឡើងថា៖** *“បុគ្គលគ្រប់ៗរូប មានភាពស្មើគ្នានៅចំពោះមុខច្បាប់ និងមានសិទ្ធិទទួលបានការការពារស្មើគ្នាពីច្បាប់ដោយគ្មានការរើសអើងឡើយ។ ទោះបីជាស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ មិនបានទាមទារសិទ្ធិពិសេស ឬសិទ្ធិបន្ថែមណាមួយក្តី ប៉ុន្តែសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់ពួកគាត់ រួមទាំងសិទ្ធិទទួលបានការងារធ្វើសមស្រប មិនគួរត្រូវបានបដិសេធនោះទេ។ រដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា ត្រូវតែធានាឲ្យបាននូវលក្ខខណ្ឌ និងឱកាសទទួលបានការងារស្មើគ្នាដល់ប្រជាពលរដ្ឋគ្រប់រូប ដោយមិនគិតពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រពិតប្រាកដ ឬសន្ទតរបស់ពួកគាត់ឡើយ។ រាជរដ្ឋាភិបាលកម្ពុជាគួរតែ (១) ស្នើឲ្យមានវិសោធនកម្មរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការងារ ដើម្បីបញ្ចូលវាក្យសព្ទ “និន្នាការភេទ” និង ”អត្តសញ្ញាណយេនឌ័រ” (២) អនុម័តច្បាប់ប្រឆាំងនឹងការរើសអើង (៣) បង្កើតនូវគោលនយោបាយច្បាស់លាស់មួយ លើបញ្ហាអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ឧទាហរណ៍ ការបញ្ចូលនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ទៅក្នុងយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាពនៅកម្ពុជា។”*

សម្រាប់ពត៌មានបន្ថែម សូមទាក់ទង **លោក ហែម សុខលី** តាមរយៈ**លេខទូរស័ព្ទ** +៨៥៥ (0) ៩២ ៨០៥ ៨០៨ ឬតាមរយៈ**អ៊ីម៉ែល**
soklyhem@cchrcambodia.org